ឆ្នាំទី2៖ លេខ 9/ខែមិថុនា ឆ្នាំ2026

EQUITY ENGAGEMENT & PARTNERSHIPS
LONG BEACH UNIFIED SCHOOL DISTRICT

# ព្រឹត្តិបត្រព័ត៌មាន

@lbusdengage | lbschools.net/engage

LONG BEACH UNIFIED • SCHOOL • DISTRICT Excellence and Equity




## ព័ត៌មានសំខាន់ៗ

នៅក្នុងការប្រជុំ C.A.F.E. ចុងក្រោយប្រចាំឆ្នាំ គឺមានការធ្វើបទបង្ហាញដោយបុគ្គលិកមកពីឱទ្យាន និងកម្មវិធីកំសាន្តប្រចាំក្រុង ឡុងបីច និងបណ្ណាល័យសាធារណៈប្រចាំក្រុង ឡុងបីច។ ក្រុមគ្រួសារបានរៀនអំពីធនធាន និងកម្មវិធីដែលនឹងមានបើកទទួលនៅពេលរដូវក្តៅនេះ។

## ធនធាននៅពេលរដូវក្តៅ

(Click on the images)







## រួមគ្នា គឺយើងកំពុងតែកសាងអនាគតកាន់តែប្រសើរ—នៅក្នុង និងនៅជាមួយសហគមន៍របស់យើង!

នៅពេលដែលយើងជិតឈានចូលដល់ការបញ្ចប់ឆ្នាំសិក្សា ព្រឹត្តិបត្រព័ត៌មានចុងក្រោយមកពីការិយាល័យសមធម៌ ការចូលរួម និងភាពជាដៃគូ (EEP) ធ្វើការឆ្លុះបញ្ចាំងទាំងការអបអរសាទរ ទាំងអំណរគុណសម្រាប់ឆ្នាំសិក្សាមួយ ដែលស្របដោយសហការដ៏ជ្រៅជាមួយសហគមន៍សាលារៀនរបស់យើង។ នៅទូទាំងរយៈពេល 5 ឆ្នាំកន្លងមក យើងខ្ញុំនៅតែកាន់ការប្តេជ្ញាចិត្ត ដើម្បីធ្វើការយកចិត្តទុកដាក់ទទួលមតិកែលម្អ បទពិសោធន៍ និងអនុសាសន៍ផ្សេងៗមកពីក្រុមគ្រួសារ សិស្ស បុគ្គលិក និងដៃគូផ្សេងៗក្នុងសហគមន៍ និងដើម្បីពង្រឹងការរួមចំណែកដ៏មានអត្ថន័យក្នុងការគាំទ្រសាលារៀនឱ្យមានជាសមធម៌ និងភាពស្វាគមន៍កាន់តែច្រើនឡើង។

នៅក្នុងការចុះផ្សាយចុងក្រោយនេះ យើងខ្ញុំលើកបង្ហាញព័ត៌មានសំខាន់ៗមកពីការប្រជុំ CAFE និងការប្រជុំ DCAC ចុងក្រោយប្រចាំឆ្នាំ ចែករំលែកកម្មវិធីផ្សេងៗនៅពេលរដូវក្តៅ ដែលត្រូវបានរៀបចំឡើង ដើម្បីគាំទ្រជាបន្តចំពោះការសិក្សា ការធ្វើទំនាក់ទំនង និងការចូលរួមជាមួយសហគមន៍សាលារៀនរបស់យើង និងដើម្បីផ្តល់ឱកាសចុងក្រោយសម្រាប់លោកអ្នកផ្តល់មតិកែលម្អលើផែនការ LCAP ដែលជាដំណើរការមួយចំណែកក្នុងការពិនិត្យសើរើជាសាធារណៈ។ យើងខ្ញុំសូមថ្លែងអំណរគុណដោយស្មោះស្ម័គ្រចំពោះលោកអ្នកទាំងអស់ ដែលបានចំណាយពេលចូលរួមនៅទូទៅឆ្នាំសិក្សា ផ្តល់មតិកែលម្អ និងកសាងភាពជាដៃគូក្នុងការកង្កើតបាននូវកិច្ចការដ៏សំខាន់មួយនេះ រួមជាមួយការិយាល័យរបស់យើងខ្ញុំ។

Dr. Lucy Salazar



# ព័ត៌មានថ្មីៗអំពីថវិកានៃខែមិថុនា

**ការកែសម្រួលថវិកានៅខែឧសភា**បាននាំមកនូវព័ត៌មានវិជ្ជមានមួយចំនួនសម្រាប់ចំណូលពីរដ្ឋរបស់មន្ទីរអប់រំឡុងប៊ីច (Long Beach Unified) ដែលមានរួមជាការកែតម្រូវថ្លៃរស់នៅ (COLA) បន្ថែមចំនួន 1.44% នៅក្នុងរូបមន្តផ្តល់មូលនិធិគ្រប់គ្រងប្រចាំមូលដ្ឋាន (LCFF) ចំណូលបន្ថែមដែលទទួលបានតែម្តង និងមូលនិធិបន្ថែមសម្រាប់កម្មវិធីនានា ដូចជាកម្មវិធីអប់រំពិសេស ជាដើម។ ទោះជាយ៉ាងណាក្តី គឺគួរឱ្យកត់សម្គាល់ថា មន្ទីរអប់រំនៅតែប្រឈមមុខនឹងបញ្ហាថវិការយៈពេលវែង ដែលបណ្តាលមកពីការថយចុះនៃការចុះឈ្មោះសិស្ស អត្រាវត្តមានទាបជាងមុនសម័យជម្ងឺរាតត្បាត និងការកើនឡើងនៃការចំណាយផ្សេងៗ។ ទោះបីជាការកែសម្រួលថវិកានៅខែឧសភាបានផ្តល់ពេលវេលាបន្ថែមដល់មន្ទីរអប់រំក្នុងការដោះស្រាយបញ្ហាទាំងនេះក៏ដោយ ក៏ការរៀបចំផែនការ និងសកម្មភាព នៅតែបន្តធ្វើទៀត ដើម្បីធានាបាននូវស្ថិរភាពហិរញ្ញវត្ថុក្នុងរយៈពេលវែង។ មានសេចក្តីរំពឹងទុកថា មន្ទីរអប់រំនឹងចំណាយលើសពីចំណូលដែលខ្លួនទទួលបានសម្រាប់ឆ្នាំទីបីជាប់ៗគ្នា។ ការចំណាយលើសចំណូលនេះកើតឡើងជាចម្បងដោយសារការថយចុះនៃចំណូល ដែលការចំណាយលើអត្ថប្រយោជន៍បុគ្គលិក ការដឹកជញ្ជូន សេវាសាធារណូបករណ៍ និងសេវាកម្មវិធីអប់រំពិសេស គឺនៅតែបន្តកើនឡើង។




lbschools.net/budget.

## ក្រុមប្រឹក្សាភិបាលអប់រំ – ព័ត៌មានថ្មីៗអំពីថវិកា និង ពង្រាង LCAP #2




## ផែនការគ្រប់គ្រង និងគណនេយ្យភាពប្រចាំមូលដ្ឋាន (LCAP)



# ទិដ្ឋភាពទូទៅប្រចាំឆ្នាំ



# ទិដ្ឋភាពទូទៅប្រចាំឆ្នាំ










Parenting Partners





